**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ:...០៦..៧.៣៤...កសក

# សេចក្តីសំរេច
## ស្តីពី
## ការបង្កើតក្រុមការងារ គ្រប់គ្រងផលិតផលកសិកម្ម ដែលបានមកពី សរីរាង្គបំរែបំរួលដោយហ្សែន

*********

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ: នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ: ០២ នស/ រកត/ ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ: នស/រកម/ ០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ: ១៧ អនក្រ.បកចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញគោលការណ៍អាស៊ាន ស្តីពីការវាយតំលៃនូវភាពគ្រោះថ្នាក់ អំពីសរីរាង្គបំរែបំរួល ផ្នែកហ្សែនទាក់ទង និងកសិកម្ម
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## <u>សំរេច</u>

**<u>ប្រការ១</u>** : សំរេចបង្កើតក្រុមការងារ ដែលហៅថា : ក្រុមការងារគ្រប់គ្រងផលិតផលកសិកម្ម ដែលបានមកពីសរីរាង្គបំរែបំរួលដោយហ្សែន ដែលហៅជាភាសាអង់គ្លេសថា : Working Group on Agricultural Products Derived from Genetically Modified Organisms (GMOs) ។

**ប្រការ២:** ក្រុមការងារ គ្រប់គ្រងផលិតផលកសិកម្ម ដែលបានមកពីសរីរាង្គបំរែបំរួលដោយហ្សែន មានសមាសភាព ដូចខាងក្រោម:

| | |
|---|---|
| ១- ប្រធាន នាយកដ្ឋានក្សេត្រសាស្ត្រ | ប្រធាន |
| ២- ប្រធាន នាយកដ្ឋាន ផលិតកម្ម និង បសុព្យាបាល | អនុប្រធាន |
| ៣- ប្រធាន នាយកដ្ឋានជលផល | សមាជិក |
| ៤- ប្រធាន នាយកដ្ឋាន រុក្ខាប្រមាញ់ | សមាជិក |
| ៥- ប្រធានវិទ្យាស្ថានស្រាវជ្រាវ និង អភិវឌ្ឍន៍កសិកម្មកម្ពុជា | សមាជិក |
| ៦- ប្រធាននាយកដ្ឋាន ផ្សព្វផ្សាយកសិកម្ម | សមាជិក |
| ៧- ប្រធាននាយកដ្ឋាន នីតិកម្មកសិកម្ម | សមាជិក |
| ៨- ប្រធានការិយាល័យអាស៊ានកសិកម្ម | សមាជិក |

**ប្រការ៣ :** ក្រុមការងារ គ្រប់គ្រងផលិតផលកសិកម្ម ដែលបានមកពី សរីរាង្គបំរែបំរួលដោយហ្សែន GMOs មាន ភារកិច្ច ដូចខាងក្រោម:

ក- តាមដានគ្រប់គ្រងរាល់បណ្តាផលិតផលកសិកម្ម ក្នុងស្រុកទាំងអស់ចំពោះការផលិតចេញ ដែលមាន ពាក់ព័ន្ធជាមួយ GMOs ។

ខ- តាមដាននូវរាល់បណ្តាផលិតផលកសិកម្មទាំងអស់ ដែលនាំចូលមកពីបរទេស ហើយផលិតផល នោះជាផលិតផល ដែលបានមកពី GMOs ។

គ- ក្រុមការងារត្រូវធ្វើរបាយការណ៍ជាបន្ទាន់ ជូនថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅពេលណាពិនិត្យឃើញថា មានផលិតផលកសិកម្ម ដែលបានមកពី GMOs ដែលប្រជាពលរដ្ឋ បាននឹងកំពុងប្រើប្រាស់ និងអាចមានផលប៉ះពាល់ដល់សុខភាពប្រជាពលរដ្ឋ ។

ឃ- សំរបសំរួលការងារជាមួយបណ្តាប្រទេស ជាសមាជិកអាស៊ានទទួលបន្ទុក GMOs ដើម្បីប្រមូល ទិន្នន័យពតិមាន ស្តីពីចរាចរទំនិញកសិកម្ម ដែលបានមកពី GMOs ផលប៉ះពាល់ដល់សុខភាព របស់ផលិតផល កសិកម្ម GMOs ។

ង- ធ្វើការផ្សព្វផ្សាយអោយបានទូលំទូលាយដល់សាធារណៈជន ប្រជាពលរដ្ឋ អំពីផលិតផលកសិកម្ម ដែលបានមកពី GMOs និងផលអាចប៉ះពាល់គ្រោះថ្នាក់ដល់សុខភាពរបស់ផលិតផលទាំងនោះ ។

**ប្រការ៤** : ក្រុមការងារ គ្រប់គ្រងផលិតផលកសិកម្ម ដែលបានមកពី សរីរាង្គបំរែបំរួលដោយហ្សែន GMOs ប្រើប្រាស់ នាយកដ្ឋានកេរ្យត្រសាស្ត្រ និងកែលំអដីកសិកម្ម ជាលេខាធិការដ្ឋានរបស់ខ្លួន ។

**ប្រការ៥** : រាល់លទ្ធផលការងារ ដែលទទួលបាន ប្រធានក្រុមការងារគ្រប់គ្រងផលិតផលកសិកម្ម ដែលបានមកពីសរីរាង្គបំរែបំរួលដោយហ្សែន ត្រូវរាយការណ៍ជូនថ្នាក់ដឹកនាំ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ពិនិត្យ និងសំរេច ។

**ប្រការ៦**: អគ្គនាយក្រសួង អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានកេរ្យត្រសាស្ត្រ និង កែលំអដីកសិកម្ម ប្រធាននាយកដ្ឋានផលិតកម្ម និងបសុព្យាបាល ប្រធាននាយកដ្ឋានរុក្ខាប្រមាញ់ ប្រធាននាយកដ្ឋានជលផល ប្រធាននាយកដ្ឋានផែនការ-ស្ថិតិ និងសហប្រតិបត្តិការអន្តរជាតិ និងដូចមានចែងក្នុងប្រការ២ នៃក្រុមការងារ គ្រប់គ្រងផលិតផលកសិកម្ម ដែលបានមកពីសរីរាង្គបំរែបំរួលដោយហ្សែន ត្រូវអនុវត្តតាមសេចក្តីសំរេច នេះអោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី 15 ខែ ០1 ឆ្នាំ២០០២

ជ័នុ-ឃារុន

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងពត៌មាន
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងបរិស្ថាន
- រដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ

  " ដើម្បីជូនជ្រាប"

- ដូចប្រការ ៦

  " ដើម្បីអនុវត្តន៍"

- ឯកសារ-កាលប្បវត្តិ